ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 31 / 01 / 2013
ម៉ោង (Time/Heure): 15:30
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier:

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

## អនុស្សរណៈ-អង្គជំនុំជម្រះសាលាដំបូង

សាធារណៈ / Public

ថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១៣

**ជូនចំពោះ÷** ភាគីនៃសំណុំរឿង ០០២

**ពី÷** ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង

**ចម្លងជូន÷** លោក /លោកស្រីចៅក្រមទាំងអស់ និងមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង

**កម្មវត្ថុ÷** ចម្លើយតបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាសុំដាក់ទៅក្នុងសំណុំរឿងនូវខ្សែវីដេអូ នៃបទបង្ហាញរបស់សាក្សីជំនាញ Philip SHORT (ឯកសារ E260/1)

១. យោងសំណើខាងលើ ដែលលើកឡើងអំពីសម្រង់សង្ខេបខ្សែវីដេអូនៃបទបង្ហាញមួយរបស់អ្នកជំនាញ Philip SHORT ដែលអង្គជំនុំជម្រះបានអនុញ្ញាតឱ្យសហព្រះរាជអាជ្ញាលើកឡើងក្នុងអំឡុងពេលអ្នកជំនាញរូបនេះផ្តល់សក្ខីកម្ម (ឯកសារ E260)។ នៅពេលមានសំណើសុំរបស់សហព្រះរាជអាជ្ញានោះ ខ្សែវីដេអូអំពីបទបង្ហាញខាងលើមានតែនៅលើប្រព័ន្ធអ៊ីនធឺណែតប៉ុណ្ណោះ។ ដោយហេតុថាចាប់តាំងពីពេលនោះមកសហព្រះរាជអាជ្ញាមានលទ្ធភាពដើម្បីទទួលបានខ្សែអាត់វីដេអូនេះនោះ នាពេលបច្ចុប្បន្ននេះសហព្រះរាជអាជ្ញាស្នើសុំការអនុញ្ញាតដើម្បីដាក់ខ្សែអាត់វីដេអូនេះនៅក្នុងសំណុំរឿង ដើម្បីធ្វើយ៉ាងណាឱ្យ ភាគីអាចមានលទ្ធភាពពិនិត្យមើលវីដេអូនេះបាន ដើម្បីបង្កើតកំណត់ហេតុឱ្យបានកាន់តែពេញលេញអំពីភស្តុតាងរបស់អ្នកជំនាញនៅក្នុងសំណុំរឿងនេះ និងកាត់បន្ថយហានិភ័យនៃបញ្ហាបច្ចេកទេស ប្រសិនបើខ្សែអាត់វីដេអូនេះត្រូវបានពិនិត្យមើល *តាមរយៈ* ប្រព័ន្ធអ៊ិនធឺណែតក្នុងអំឡុងពេលលោក SHORT ផ្តល់សក្ខីកម្ម។

២. អង្គជំនុំជម្រះឯកភាពតាមសំណើនេះ។ អង្គជំនុំជម្រះស្នើថានៅពេលភាគីប្រឈមជាមួយសំណើស្រដៀងនេះ ភាគីគួរគប្បីលើកបញ្ហាទាំងនេះទៅមន្ត្រីច្បាប់ជាន់ខ្ពស់ជំនួសវិញ ដើម្បីអាចទទួលបានដំណោះស្រាយក្រៅផ្លូវការលើបញ្ហានេះ។